**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

លេខ ០០៤ សណន

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០២១

**សេចក្តីណែនាំ**

**ស្តីពី**

**ការបន្តពង្រឹងការអនុវត្តគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល និងវិធានសុវត្ថិភាពទេសចរណ៍នៅតាមមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ក្នុងរាជធានី ខេត្ត**

អនុវត្តតាមបទបញ្ជាដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នាយប់ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ ក្រសួងទេសចរណ៍ សូមក្រើនរំលឹកដល់មន្ទីរទេសចរណ៍រាជធានី ខេត្ត ធ្វើសហការជាមួយអង្គភាពជំនាញពាក់ព័ន្ធបន្តយកចិត្តទុកដាក់ពង្រឹងការអនុវត្តជាប្រចាំនូវគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល និងវិធានសុវត្ថិភាពទេសចរណ៍នៅតាមមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ក្នុងរាជធានី ខេត្ត ដែលក្នុងនោះរួមមាន៖

១. ត្រូវផ្សព្វផ្សាយ និងអនុវត្តឱ្យបានជាប្រចាំនូវអនុសាសន៍ណែនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នូវវិធានការ **"៣ ការពារ ៣ កុំ"** ឱ្យបានម៉ឺងម៉ាត់បំផុត។

២. ណែនាំដល់មូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ រមណីយដ្ឋាន និងសហគមន៍ទេសចរណ៍ទាំងអស់ រៀបចំជាជនបង្គោល និងវេនប្រចាំការ។ នៅតាមមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ រមណីយដ្ឋាន និងសហគមន៍ទេសចរណ៍ នានា ការជួបជុំកម្សាន្តតាមបែបប្រមូលផ្តុំត្រូវបានហាមឃាត់។

៣. ត្រូវបន្តអនុវត្តសេចក្តីណែនាំលេខ ០១០ សណន ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២០ ស្តីពីវិធានការការពារការចម្លងវីរុសកូវីដ១៩ (COVID-19) សម្រាប់អាជីវកម្មទីលានវាយកូនគោល (Golf Course) ឱ្យមានប្រសិទ្ធភាព។

៤. ចំពោះវិធានសុវត្ថិភាពទេសចរណ៍ (ជំហានទី១) ដែលបានដាក់ចេញឱ្យអនុវត្តកន្លងមក ក្នុងនោះរួមមាន វិធានសុវត្ថិភាពទេសចរណ៍សម្រាប់សេវាកម្មស្នាក់នៅទេសចរណ៍ សេវាកម្មភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ សេវាកម្មដឹកជញ្ជូនទេសចរណ៍ផ្លូវទឹក និងផ្លូវគោក សេវាកម្មរមណីយដ្ឋានទេសចរណ៍ និងសហគមន៍ទេសចរណ៍ ត្រូវបន្តយកចិត្តទុកដាក់ផ្សព្វផ្សាយឱ្យកាន់តែផុលផុស និងអនុវត្តឱ្យបានជាប្រចាំជាងមុនបន្ថែមទៀត តាមរយៈក្រុមការងារបានបង្កើតឡើង។

៥. រឹតបន្តឹងសន្តិសុខសណ្តាប់ធ្នាប់ក្នុងបរិវេណមូលដ្ឋានអាជីវកម្ម នៅច្រកចូល ឬច្រកចេញដោយតម្រូវឱ្យមានការពិនិត្យវាស់កម្តៅ លាងសំអាតដៃ និងស្កេន **QR CODE** ទប់ស្កាត់កូវីដ១៩ **(STOP COVID-19)** និងមិនត្រូវអនុញ្ញាតឱ្យមានការជួបជុំ ប្រមូលផ្តុំគ្នា។

អគារលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

៦. ស្នើបន្តរឹតបន្តឹង "ការបិទ" ចំពោះប្រភេទអាជីវកម្ម សេវាកម្មទាំងឡាយណា ដែលកន្លងមក ពុំត្រូវបានអនុញ្ញាតឱ្យធ្វើអាជីវកម្មក្នុងដំណាក់កាលចូលរួមទប់ស្កាត់ការចម្លងដោយជំងឺកូវីដ១៩ ឱ្យបានជាប់ជាប្រចាំ។

៧. គ្រប់មូលដ្ឋានអាជីវកម្ម សេវាកម្ម រមណីយដ្ឋាន សហគមន៍ទេសចរណ៍ទាំងអស់ត្រូវបង្កើនការលើកកម្ពស់ស្មារតីប្រុងប្រយ័ត្ន និងទទួលខុសត្រូវខ្ពស់ក្នុងដំណាក់កាលនេះ។ ការល្មើសនឹងបទបញ្ជា ត្រូវទទួលពិន័យទោសតាមបទប្បញ្ញត្តិជាធរមាន។

ទទួលបានសេចក្តីណែនាំនេះ សូម **លោក លោកស្រីប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត** ត្រូវចាត់ចែងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសុខាភិបាល
- គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ១៩
- ខុទ្ទកាល័យ**សម្តេចតេជោនាយករដ្ឋមន្ត្រី**
- សាលារាជធានី ខេត្ត
- មន្ទីរទេសចរណ៍រាជធានី ខេត្ត "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ